**ប្រការ ៣** : នាយកខុទ្ទកាល័យ ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានពន្ធដារ និង អង្គភាពដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ។

ហត្ថលេខា និង ត្រា

**គាត ឈន់**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ១៩៩៦

**ប្រកាសលេខ ១៧២ ប្រក.សហវ.ពដ**

**ការបង្កើតការិយាល័យបទិនាន**

ទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។
- បានឃើញព្រះរាជក្រឹត្យ ន.ស.រកត ១០៩៤.៩៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ នស.រកម ០១៩៦.១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ។
- បានឃើញច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ និងច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០៨ ន.ស ៩៤ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់គ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ ១១.នស.៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ច្បាប់ស្តីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយ

ប្រើដោយព្រះរាជក្រម ជស.រកម.០៩៩៥.០១ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥

–បានឃើញតំរូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

– តាមសំណើរបស់ប្រធាននាយកដ្ឋានពន្ធដារ ។

**សំរេច**

**ប្រការ ១** : ត្រូវបានបង្កើតក្នុងនាយកដ្ឋានពន្ធដារ នូវការិយាល័យវិវាទ ។

**ប្រការ ២** : ការិយាល័យនេះមានភារកិច្ច ។

– គ្រប់គ្រងរាល់វិវាទកើតមានឡើងរវាងអ្នកជាប់ពន្ធ និង រដ្ឋបាលសារពើមាន

– ស្វែងយល់លើរាល់ការតវ៉ារបស់អ្នកជាប់ពន្ធ ចំពោះគ្រប់កិច្ចការដែលជាសមត្ថកិច្ចផ្ទាល់របស់នាយកដ្ឋាន និង ការតវ៉ាទាំងឡាយដែលមិនអាចដោះស្រាយបាននៅក្នុងក្របខ័ណ្ឌមូលដ្ឋាន

– រៀបចំសេចក្តីសំរេចរបស់លោកប្រធាន ឬ សេចក្តីសំរេចទាំងឡាយ សំរាប់ដាក់ជូនរដ្ឋមន្ត្រីទៅតាមសមត្ថកិច្ច

– ធានាទំនាក់ទំនងជាមួយនឹងតុលាការ

– រៀបចំចាត់តែងជាផលប្រយោជន៍ដល់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លើរាល់ពាក្យបណ្តឹងធ្វើឡើងដោយក្រសួងទៅតុលាការ

– ប្រមូលផ្តុំរាល់ស្ថិតិវិវាទ ពាក់ព័ន្ធដល់មូលដ្ឋានកំណត់ពន្ធ ។

**ប្រការ ៣** : នាយកខុទ្ទកាល័យ ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានពន្ធដារ និង អង្គភាពដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ។

ហត្ថលេខា និង ត្រា

**គាត ឈន់**

* * *